**ស្ថានទូតអូស្ត្រាលី**

**ប្រចាំព្រះរាជាណាចក្រកម្ពុជា**

**<u>សេចក្តីប្រកាសព័ត៌មាន</u>**

ថ្ងៃទី៥ ខែមេសា ឆ្នាំ ២០២៤

# ពិធីសម្ពោធកម្មវិធីសហប្រតិបត្តិការអូស្ត្រាលី–កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌–ដំណាក់កាលទី២

ថ្ងៃនេះ ឯកឧត្តម ចាស្ទីន វ៉ាយអេត ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំនៅប្រទេសកម្ពុជា រួមជាមួយឯកឧត្តម លោកជំទាវរដ្ឋមន្ត្រីកម្ពុជា បានបើកសម្ពោធជាផ្លូវការនូវ កម្មវិធីសហប្រតិបត្តិការអូស្ត្រាលី–កម្ពុជា ដើម្បីការផ្តល់សេវាប្រកបដោយនិរន្តរភាព និងសមធម៌-ដំណាក់កាលទី២ (ACCESS 2)។

លោកជំទាវកិត្តិបណ្ឌិត អ៊ឹង កន្ថាផាវី រដ្ឋមន្ត្រីក្រសួងកិច្ចការនារី ឯកឧត្តមសាស្ត្រាចារ្យ ឈាង រ៉ា រដ្ឋមន្ត្រីក្រសួងសុខាភិបាល និងឯកឧត្តម ជា សុមេធី រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាសកម្មភាពជនពិការ បានអញ្ជើញចូលរួមជាមួយ ឯកអគ្គរដ្ឋទូត វ៉ាយអេត ដើម្បីចុះហត្ថលេខាលើអនុស្សរណៈនៃកិច្ចព្រមព្រៀងកម្មវិធី ACCESS 2។

កម្មវិធីនេះ បន្តសកម្មភាពជំនួយទ្វេភាគីដ៏សំខាន់របស់ប្រទេសអូស្ត្រាលី លើការងារបរិយាបន្នពិការភាព និងការឆ្លើយតបនិងការការពារអំពើហិង្សាទាក់ទងនឹងយេនឌ័រ នៅប្រទេសកម្ពុជា។ ក្នុងរយៈពេល៥ឆ្នាំ (២០២៣ – ២០២៨) រដ្ឋាភិបាលអូស្ត្រាលីនឹងផ្តល់ថវិកាចំនួន ៣០លានដុល្លារអូស្ត្រាលី ដើម្បីធ្វើអោយប្រសើរឡើងនូវគុណភាព និងការសម្របសម្រួលការផ្តល់សេវាដល់ ជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹងយេនឌ័រ និងជនមានពិការភាព នៅប្រទេសកម្ពុជា។

ឯកអគ្គរដ្ឋទូត វ៉ាយអេត បានមានប្រសាសន៍ថា "កម្មវិធី ACCESS 2 ឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តយ៉ាងមុតមាំរបស់រដ្ឋាភិបាលអូស្ត្រាលី ក្នុងការគាំទ្រការអភិវឌ្ឍប្រកបដោយបរិយាបន្នពិការភាព និងសមភាពយេនឌ័រនៅក្នុងតំបន់របស់យើង ព្រោះនេះជាគុណតម្លៃស្នូលរបស់ប្រទេសអូស្ត្រាលី និងជាអាទិភាពចម្បងនៅក្នុងគោលនយោបាយអភិវឌ្ឍន៍អន្តរជាតិថ្មីរបស់រដ្ឋាភិបាលអូស្ត្រាលី"។

កម្មវិធី ACCESS 2 នឹងបន្តធ្វើការជាមួយរាជរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីធានាថាជនមានពិការភាព និងជនរងគ្រោះដោយអំពើហិង្សាទាក់ទងនឹង យេនឌ័រ ទទួលបានសេវាដែលពួកគេត្រូវការ។

តាមរយៈបណ្តាដៃគូអនុវត្តកម្មវិធីរបស់អង្គការសហប្រជាជាតិ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ១៣ កម្មវិធី ACCESS 2 នឹងបន្តធ្វើការជាមួយក្រសួងកិច្ចការនារី ក្រសួងសុខាភិបាល និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ដើម្បីអនុវត្តផែនការសកម្មភាពជាតិរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការទប់ស្កាត់អំពើហិង្សាលើស្ត្រី និងផែនការយុទ្ធសាស្ត្រជាតិស្តីពីពិការភាព។

ព័ត៌មានបន្ថែមអំពីកម្មវិធីACCESS 2 សូមចូលទៅកាន់គេហទំព័រ៖ www.access2cambodia.org

**ទំនាក់ទំនងព័ត៌មាន៖** Media.Cambodia@dfat.gov.au